**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Aug-2011, 15:06
CMS/CFO: Kauv Keoratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនគោរពតាមដីការរបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យផ្តល់បញ្ជីភស្តុតាង និង ឧត្តុតាងដែលពួកគេមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ**

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Michael Ramsden (កម្មសិក្សាការីច្បាប់)

Tom Hamilton (កម្មសិក្សាការីច្បាប់)

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

ពេជ អង្គ

Elisabeth SIMONNEAU FORT

## I. សេចក្តីផ្តើម

១. អនុលោមតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អវតក មេធាវីការពារក្តី នួន ជា (ក្រុមមេធាវីការពារក្តី) តទៅនេះសូមដាក់សារណាឆ្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនគោរពតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យផ្តល់បញ្ជីឯកសារ និងវត្ថុតាងដែលពួកគេមានបំណងដាក់នៅអង្គជំនុំជម្រះ ("សំណើរបស់ កសព") ។ សម្រាប់ហេតុផលទាំងអស់ដែលបញ្ជាក់នៅខាងក្រោមនេះ ក្រុមមេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញា ដោយសារខបាស្រ័យជាដំណោះស្រាយដែលបានស្នើសុំនេះ រំលោភមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ បើសិនជាអង្គជំនុំជម្រះសាលាដំបូងមិនបដិសេធចោលទាំងស្រុងនូវសំណើរបស់ កសព ទេ អង្គជំនុំជម្រះគប្បីបញ្ជូនបញ្ហានេះទៅក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីការបស់ខ្លួនបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ[1] ដែលនៅក្នុងដីកានោះអង្គជំនុំជម្រះបង្គាប់ឲ្យភាគីដាក់បញ្ជី(យ៉ាងខ្លី)ឯកសារ និងវត្ថុតាងដែលពួកគេមានបំណងលើកឡើងក្នុងអំឡុងពេលសវនាការមិនឲ្យលើសពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១ ។ ក្នុងអំឡុងពេលសវនាការបឋម អង្គជំនុំជម្រះបានចេញដីកាជាលើកទីពីរដែលបង្គាប់(យ៉ាងខ្លី)ឲ្យភាគីដាក់មិនឲ្យលើសពីថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ នូវបញ្ជីឯកសារ និងវត្ថុតាងដែលពាក់ព័ន្ធទៅនឹង"សវនាការផ្នែកដំបូង"[2] ។ ដីកាទាំងពីរនេះហៅថា "ដីកាបង្គាប់ត្រៀមរៀបចំសវនាការ" ។

៣. សហព្រះរាជអាជ្ញានៅថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១១ បានដាក់សំណើរបស់ខ្លួនទាក់ទងនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនគោរពតាមដីការបស់អង្គជំនុំជម្រះសាលាដំបូង

---

[1] ឯកសារ E9 ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ERN 00635754-00635759 ។

[2] ឯកសារ E1/4/.1 ប្រតិចារិកនៃសវនាការចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ERN 00712161 ។

បង្គាប់ឱ្យផ្តល់បញ្ជីឯកសារ និងវត្ថុតាង ដែលពួកគេមានបំណងដាក់នៅអង្គជំនុំជម្រះ ។ សហព្រះរាជអាជ្ញាបានស្នើអង្គជំនុំជម្រះឱ្យច្រានចោលជាមុនមិនឱ្យក្រុមមេធាវីការពារក្តី នួន ជា បង្ហាញនៅសវនាការនូវឯកសារនានាដែលមិនត្រូវបានកំណត់អត្តសញ្ញាណកម្ម ដោយអនុលោមតាមដីកាបង្គាប់ត្រៀមរៀបចំសវនាការ ។ ជាជម្រើសម្យ៉ាងទៀត អង្គជំនុំជម្រះបង្គាប់ឱ្យជនជាប់ចោទដាក់បញ្ជីឯកសារ និងវត្ថុតាងនានាឱ្យបានត្រឹមត្រូវនៅក្នុងរយៈពេលពីរសប្តាហ៍ តែបើខកខានមិនបានធ្វើយ៉ាងដូច្នេះទេ គាត់នឹងត្រូវដាក់ទណ្ឌកម្មដោយការច្រានចោលជាមុនបែបដូច្នេះ[3] ។

៤. នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១១ នៅក្នុងនីតិវិធីដាច់ដោយឡែកមួយតែជាប់ពាក់ព័ន្ធនឹងគ្នា អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនលើអញ្ញត្រកម្មរបស់ នួន ជា ដែលពាក់ព័ន្ធទៅនឹងការប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អវតក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ("សេចក្តីសម្រេចអំពីអញ្ញត្រកម្ម") ដែលអង្គជំនុំជម្រះបានប្រកាសថាអញ្ញត្រកម្មនេះគឺមិនអាចទទួលយកបាន និងគ្មានមូលដ្ឋាន និងបានបដិសេធលើសំណើរបស់ជនជាប់ចោទសុំមោឃភាពដីកាបង្គាប់ត្រៀមរៀបចំសវនាការ[4] ។

## III. ច្បាប់ពាក់ព័ន្ធ

### ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

៥. មាត្រា ៥១ និង មាត្រា ៩០ នៃរដ្ឋធម្មនុញ្ញចែងថា "អំណាចនីតិបញ្ញត្តិ អំណាចប្រតិបត្តិ និងអំណាចតុលាការ ត្រូវបែងចែកដាច់ពីគ្នា[5] [...] ហើយថារដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិ ។ អំណាចនេះរដ្ឋសភាមិនអាចប្រគល់ទៅឱ្យអង្គការ ឬបុគ្គលណាមួយបានឡើយ [...][6] ។

---

[3] ឯកសារ E109/5 "សំណើរបស់ កសព ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១, ERN 00722647-00722659 ។

[4] ឯកសារ E51/14 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយនៃវិធានផ្ទៃក្នុងរបស់ អវតក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ERN 00635754-00635759 ។

[5] មាត្រា ៥១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (សម្រង់) ។

[6] មាត្រា ៩០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (បញ្ជាក់បន្ថែម) ។

៦. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមច្បាប់បញ្ញត្តិ"។ មាត្រា ១១០ នៃរដ្ឋធម្មនុញ្ញចែងថា "ការជំនុំជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជាពលរដ្ឋខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន" ។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញការពារសិទ្ធិមនុស្សរបស់ នួន ជា ដូចដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សជាច្រើន ។

## ខ. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

៧. មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថាៈ បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័ននានាដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន។ បើយល់ឃើញថាការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ ។ តុលាការកំពូលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ ថ្ងៃយ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានោះមិនអាចទទួលបាន"[7] ។

## គ. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

៨. មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថាៈ *"រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ថា មានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត [...]"*[8] ។

---

[7] មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ១៩៩៨, ព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ។ (វាជាអត្ថបទបកប្រែក្រៅផ្លូវការនៃមាត្រា ១៩ ដោយអង្គភាព ITUនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១) ហើយអត្ថបទនេះខុសគ្នាបន្តិចពីអត្ថបទដែលមានស្តុកទុកនៅក្នុងកម្រងឯកសារច្បាប់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលចងក្រងឡើងដោយលេខាដ្ឋានក្រុមការងារ ហើយដែលមានលក្ខណៈសុក្រិតច្រើនជាង) ។

[8] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ (បញ្ជាក់បន្ថែម) ។

## IV. អំណះអំណាង

### ក. ឧបាស្រ័យជាដំណោះស្រាយដែលស្នើឡើងដោយ កសព គឺផ្ទុយនឹងច្បាប់

៩. សំណើរបស់ កសព ខកខានមិនបានទទួលស្គាល់បទប្បញ្ញត្តិដ៏មានសារសំខាន់ដែលគ្រប់គ្រងដំណើរការនីតិវិធីទាំងនេះ ដែលនោះគឺមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ បទប្បញ្ញត្តិនេះចែងថា “រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោល ជនជាប់ចោទ [...] អាចធ្វើសេចក្ដីសន្និដ្ឋាន និងដាក់លិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ ដល់ការសំដែងឲ្យឃើញការពិត[9] ។

១០. ជាបទប្បញ្ញត្តិមួយដែលមានន័យយ៉ាងច្បាស់លាស់ ចែងពីសិទ្ធិយ៉ាងច្បាស់សម្រាប់ជនជាប់ចោទណាមួយ និងដែលអាចអនុវត្តបាននៅចំពោះមុខតុលាការកម្ពុជាទៀតផង ។ ពុំមានការធ្វើយុត្តិកម្មខាងផ្លូវច្បាប់សម្រាប់ការរំលោភបំពានបទប្បញ្ញត្តិនៃមាត្រានេះ ឬការធ្វើឲ្យប៉ះពាល់ដល់ការការពារដែលផ្ដល់ឲ្យដោយបទប្បញ្ញត្តិនៃមាត្រានេះឡើយ ។

១១. មាត្រា ១២(១) នៃកិច្ចព្រមព្រៀងបង្កើត អវតក ចែងថា “នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬ មានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធច្បាប់កម្ពុជា ឬមានបញ្ហាពាក់ព័ន្ធនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”។ មាត្រា ៣៣ ថ្មីនៃច្បាប់បង្កើត អវតក មានពាក្យពាចន៍ដូចគ្នា[10] ។

១២. “បញ្ហាពិសេស” ដែលជាចំណុចនៃបញ្ហានៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះ គឺថាតើ នួន ជា អាចត្រូវបានគេរាំងមិនឲ្យដាក់ឯកសារ និងវត្ថុតាង រហូតទល់នឹងការបិទសវនាការជំនុំជម្រះក្ដីរបស់គាត់ដែរ ឬអត់។ ច្បាប់កម្ពុជាដោះស្រាយយ៉ាងច្បាស់ចំពោះបញ្ហានេះនៅក្នុងមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ ហេតុនេះវាមិនមានភាពមិនច្បាស់លាស់ទាក់ទងនឹង

---

[9] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (សម្រង់) ។

[10] សូមមើលផងដែរឯកសារ 96/1, អក្សរក្នុងលេខយោងលេខ ៥ នៃសារណាឆ្លើយតបរបស់ក្រុមមេធាវីការពារក្ដី នួន ជា ទៅនឹងសេចក្ដីសន្និដ្ឋានរបស់ កសព ទាក់ទងនឹងការទទួលយកកំណត់ស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១១ ERN 00716969-ERN00716978 ។

ការបកស្រាយ ឬ ការអនុវត្តមាត្រានេះឡើយ (មាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានបញ្ញត្តិយ៉ាងច្បាស់) ហើយស៊ីសង្វាក់ទៅនឹងបទដ្ឋានអន្តរជាតិទៀតផង ។

១៣. ភាពសមស្របគ្នានៃមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទៅនឹងបទដ្ឋានអន្តរជាតិ គឺជាភស្តុតាងយ៉ាងពិតៗ។ មាត្រានេះស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ ពីព្រោះមាត្រានេះផ្តល់ឲ្យជនជាប់ចោទនូវសិទ្ធិដើម្បីដាក់ភស្តុតាងដែលពាក់ព័ន្ធនៅសវនាការជំនុំជម្រះក្តី ។ មេធាវីការពារក្តីស្នើឲ្យពិចារណាថា បទដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌ គឺជា“បទដ្ឋានអន្តរជាតិ” ដែលពាក់ព័ន្ធតែមួយគត់” សម្រាប់គោលបំណងនៃមាត្រា ១២ នៃកិច្ចព្រមព្រៀងបង្កើត អវតក នេះ ។ ប៉ុន្តែ បើសិនជាគេត្រូវពិនិត្យមើលបទដ្ឋាននីតិវិធីអន្តរជាតិសម្រាប់ការទទួលយកភស្តុតាងវិញ នោះគេពុំមានមន្ទិលសង្ស័យទេចំពោះភាពសមស្របគ្នារបស់មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទៅនឹងបទដ្ឋាននីតិវិធីអន្តរជាតិទាំងនេះទេ ។ ដើម្បីធ្វើឲ្យ “សមស្របគ្នា” មាត្រា ៣៣៤ មិនចាំបាច់ថាឲ្យដូចគ្នាសុទ្ធសាទ ឬសូម្បីតែស្រដៀងគ្នា ទៅនឹងនីតិវិធីដែលដោះស្រាយចំពោះការទទួលយកភស្តុតាងនៅតុលាការអន្តរជាតិមួយចំនួននោះទេ។ មាត្រានេះត្រូវការតែ “ភាពសមស្របគ្នា” ទៅនឹងនីតិវិធីទាំងនេះ ក្នុងន័យថា “ត្រូវគ្នា” ជាមួយនឹងនីតិវិធីទាំងនេះ[11] ។ អង្គជំនុំជម្រះសាលាដំបូងអាចយល់ឃើញថាមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្តល់ការការពារដែលមានទម្ងន់ធ្ងន់ដល់ជនជាប់ចោទ ច្រើនជាងការពារដែលមាននៅក្នុងតុលាការអន្តរជាតិនានា ដោយសារតែមាត្រានេះចែងថាភស្តុតាង អាចដាក់នៅអង្គជំនុំជម្រះរហូតទល់នឹងការបិទកិច្ចពិភាក្សាដេញ

---

[11] ការដែលថាពាក្យ“សមស្របគ្នា” ត្រូវតែយល់ក្នុងន័យថា “ត្រូវគ្នា” ជាជាងដូចគ្នាសុទ្ធសាទ ឬ ស្រដៀងគ្នា ដែលន័យវាត្រូវបានគាំទ្រដោយអត្ថបទជាភាសាបារាំងរបស់កិច្ចព្រមព្រៀងបង្កើត អវតក ដែលបានប្រើពាក្យ ‘compatibilité.’ ។ វចនានុក្រមភាសាបារាំងផ្តល់និយមន័យនៃពាក្យ compatibilité និង ពាក្យ compatible ដូចខាងក្រោម: Compatibilité [...] *de compatible.* Caractère, état de ce qui est compatible. […] **Compatible** **[…]** Qui peut s'accorder avec autre chose, exister en même temps. > **Conciliable**. *Des caractères compatibles. La fonction de préfet n'est pas compatible avec celle de député. Médicaments compatibles, pouvant être administrés en même temps.* [*Le nouveau Petit Robert de la Langue Française 2009*, Educa Books / Le Robert; Le Robert edition.] យ៉ាងច្បាស់ត្រឡែកមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងរបប ភស្តុតាងអន្តរជាតិដែលកើតមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា *អាច* ‘*exister en même temps.*’

ដោល[12] ។ ប៉ុន្តែ ចំណុចនេះ មិនបានចែងពីបទប្បញ្ញត្តិ "មិនសមស្របគ្នា" ហើយប្រាកដជា "មិនត្រូវគ្នា" ទៅនឹងបទដ្ឋានអន្តរជាតិដែរ[13] ។

១៤. បន្ថែមពីលើនេះ គេគួរចង់ចាំថាបញ្ហានេះ *មិនមែនជាបញ្ហា*ថាតើរបបភស្តុតាងដែលពិពណ៌នានៅក្នុងវិធាន ៨០ ស៊ីសង្វាក់គ្នានឹងបទដ្ឋានអន្តរជាតិដែរ ឬអត់នោះទេ[14] តែបញ្ហានៅត្រង់ថាតើមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនស៊ីសង្វាក់គ្នា (ក្នុងន័យត្រូវគ្នា compatible) ជាមួយ នឹងបទដ្ឋានអន្តរជាតិដែរ ឬអត់នោះ ។ វាពិតយ៉ាងដូច្នេះមែន ។

១៥. អាស្រ័យហេតុដូច្នេះ គេពុំអាចរកបានយុត្តិកម្មនៅក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង អវតក ឬ មាត្រា ៣៣ ថ្មីនៃច្បាប់បង្កើត អវតក ដើម្បីងាកចេញពីបទប្បញ្ញត្តិច្បាប់កម្ពុជាដែលពាក់ព័ន្ធ

---

[12] ដើម្បីសន្សំពេលវេលា មេធាវីការពារក្តីសូមដាក់បញ្ចូលសារណារបស់ខ្លួនទាក់ទងនឹងបញ្ហានេះ(តាមការកែតម្រូវចាំបាច់) ដែលមាននៅក្នុងឯកសារឯកសារ 96/1, សារណាឆ្លើយតបរបស់ក្រុមមេធាវីការពារក្តី នួន ជា ទៅនឹងសេចក្តីសន្និដ្ឋានរបស់ កសព ទាក់ទងនឹងការទទួលយកកំណត់ស្តាប់ចម្លើយរបស់សាក្សី ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១១ ERN 00716969-ERN00716978 នៅទំព័រទី៦-៨ ដែលពេលនេះស្ថិតនៅអង្គជំនុំជម្រះសាលាដំបូង ។

[13] ចំណុចនេះបង្ហាញឲ្យឃើញការពិតនៅពេលគេពិចារណាថាអង្គជំនុំជម្រះសាលាដំបូងរកឃើញការគាំទ្រដល់ការអនុម័តវិធានផ្ទៃក្នុង ដែលរួមបញ្ចូលទាំងរបបស្តីពីភស្តុតាងដែលកំពុងកើតមាននៅក្នុងនីតិវិធីពេលនេះ ដើម្បីដំណើរការនីតិវិធីសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការយុត្តិធម៌របស់ច្បាប់ ដូចដែលមានចែងនៅក្នុងមាត្រា ១៤ និង មាត្រា ១៥ នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ (ICCPR) ("សេចក្តីសម្រេចលើអញ្ញត្រកម្ម នៅកថាខណ្ឌ ៧) ដែលជាករណីកិច្ចរបស់ អវតក "ដែលមានចែងនៅក្នុងមាត្រា ៣៣ថ្មីនៃច្បាប់បង្កើត អវតក ។ បន្ទាប់មកវានឹងផ្ទុយទៅនឹងច្បាប់បើសិនអង្គជំនុំជម្រះ យកមាត្រា ១៤ និងមាត្រា ១៥ នៃ ICCPR ដែលគោលបំណងតែមួយគត់គឺផ្តល់សិទ្ធិដល់ជនជាប់ចោទដើម្បីទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មកអនុវត្តដើម្បីលុបបំបាត់ចោលសិទ្ធិរបស់ជនជាប់ចោទ តាមរយៈការប្រកាសថាវា "មិនសមស្របគ្នា" ទៅនឹងបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីយុត្តិធម៌នោះ ។

[14] អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នៅកថាខណ្ឌទី ៩ នៃសេចក្តីសម្រេចលើអញ្ញត្រកម្ម (នៅក្នុងបរិបទនៃការវាយតម្លៃដីកាបង្គាប់ត្រៀមរៀបចំសវនាការ និងអនុផ្នែកខុសគ្នានៃវិធាន ៨០) ថា "ដីកាបង្គាប់ឲ្យត្រៀមរៀបចំសវនាការ ស៊ីសង្វាក់គ្នាទៅនឹងការអនុវត្តជាអន្តរជាតិដែលដោះស្រាយជាមួយរឿងក្តីដែលមានទំហំ និងស្មុគស្មាញបែបនេះ ហើយជាបន្ទាប់អង្គជំនុំជម្រះបញ្ជាក់ថាវិធាន ៨០(៣)(ង) ស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តនៅតុលាការផ្សេងៗទៀត និងធានាសិទ្ធិរបស់ជនជាប់ចោទទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌" ។ ចំណុចនេះអាចជាការពិត (មេធាវីការពារក្តីមិនមានជំហរអ្វីទេនៅពេលនេះ) តែវាមិនមែនជាបញ្ហានៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះទេ ។ បញ្ហានៅទីនេះ គឺថាតើមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស៊ីសង្វាក់គ្នាទៅនឹង (ឬនៅក្នុងអត្ថបទជាភាសាបារាំង: *compatible*) បទដ្ឋានអន្តរជាតិ និងសិទ្ធិជាសារវន្តរបស់ជនជាប់ចោទទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែរ ឬអត់ ។

បានឡើយ ហើយជាក់ស្តែងមេធាវីការពារក្តីគួរតែអាចលើកមកសំអាងការការពាររបស់មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ វាមិនមែនជាលើកទីមួយទេ[15] កាលដែល កសព បានប៉ុនប៉ងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិដែលមានន័យយ៉ាងច្បាស់លាស់ដែលផ្តល់ឲ្យ នួន ជា នៅចំពោះមុខតុលាការកម្ពុជាក្នុងនាមជាពលរដ្ឋកម្ពុជាមួយរូប សម្រាប់គោលបំណងនៃការពន្លឿននីតិវិធី ហើយដូចពេលមុនដែរ[16] កសព ព្យាយាមបង្កើតឲ្យមានការភ័ន្តច្រឡំនៅពេលដែលគ្មានបញ្ហាបែបហ្នឹងផង ។

១៦. កសព បានអះអាងនៅក្នុងសំណើររបស់ខ្លួនថាច្បាប់កម្ពុជា "មិនបានបញ្ញត្តិ" អំពីបញ្ហាពិសេសបែបនេះទេ[17] ។ ការអះអាងបែបនេះអាចជាការពិត បើសិនជាគេចាត់ទុក "បញ្ហាពិសេសនេះ" គឺជាការដាក់បញ្ជីឯកសារនៅមុនការជំនុំជម្រះក្តី តែវាជាការមិនពិត បើសិនជាគេចាត់ទុក "បញ្ហាពិសេសនេះ" ជាបញ្ហាថាតើរហូតទល់ពេលណាដែលចុងចោទអាចដាក់ឯកសារ និងវត្ថុតាងទៅអង្គជំនុំជម្រះសាលាដំបូង[18] ។ ច្បាប់កម្ពុជាបញ្ញត្តិយ៉ាងច្បាស់អំពីបញ្ហានេះនៅក្នុង

---

[15] សូមមើលឯកសារ E96 ការសន្និដ្ឋានតាមវិធាន ៩២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០១១ ERN ERN00706071-00706086, និងជាពិសេសឯកសារ E96/1 សារណាចម្លើយតបរបស់ នួន ជា ទៅនឹងសេចក្តីសន្និដ្ឋានរបស់ កសព ទាក់ទងនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១១ ERN 00716971-ERN00716975 ។

[16] ដូចខាងលើ ។

[17] សំណើររបស់ កសព នៅត្រង់កថាខណ្ឌទី៣០ ។

[18]ជាបន្តទៅទៀតមេធាវីការពារក្តីសូមបញ្ជាក់ឡើងវិញពីការលើកឡើងនៅក្នុងសារណាឆ្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសន្និដ្ឋានរបស់ កសព ទាក់ទងនឹងការទទួយយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលបានលើកឡើងថា: "បើតាមការលើកឡើងរបស់ កសព ក្នុងករណីដែលវិធានរបស់ ICTY (ឧទាហរណ៍) មានចែងពីបញ្ហាជាក់លាក់ជាងបទបញ្ញត្តិនីតិវិធីស្រដៀងរបស់កម្ពុជា ដូច្នេះច្បាប់នីតិវិធីកម្ពុជាត្រូវចាត់ទុកថាមានចន្លោះប្រហោងដែលត្រូវបំពេញដោយច្បាប់នីតិវិធីអន្តរជាតិ។ "ការបំពេញចន្លោះប្រហោង"ច្រើនពេក -ពិតជាមិនមែនដំណើរការដែលរំពឹងទុកដោយអ្នកពង្រាងកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក ឡើយ- នឹងច្រានចោលបទបញ្ញត្តិដ៏ល្អឥតខ្ចោះរបស់កម្ពុជា ដោយមូលហេតុថាច្បាប់កម្ពុជាខ្វះភាពទាន់សម័យដូចច្បាប់អន្តរជាតិ, ឯកសារ E96/1 សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការទទួលយកកំណត់នៃការស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១១ នៅ ERN 00716973 ។

មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយហេតុដូច្នេះ វាពុំមានចន្លោះប្រហោងឯណាដែលត្រូវស្វែងរកការណែនាំការអនុវត្តជាអន្តរជាតិនោះឡើយ ។

១៧. សម្រាប់មូលហេតុទាំងនេះ ឧបាយស្រ័យជាដំណោះស្រាយដែលស្នើដោយ កសព (ជាខ្លី:ច្រានចោលភស្តុតាងដែលដាក់នៅក្រោយការចាប់ផ្តើមសវនាការលើអង្គសេចក្តី) ត្រូវតែចាត់ទុកថាជាការរំលោភដោយផ្ទាល់ទៅលើការការពារដែលផ្តល់ឲ្យជនជាប់ចោទដោយមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បន្ថែមពីលើនេះ ពុំមានយុត្តិកម្មណាដើម្បីងាកចេញពីរបបភស្តុតាងយ៉ាងច្បាស់ដូចដែលមានចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិច្បាប់កម្ពុជាដ៏សំខាន់នេះបានទេ ។ ហេតុដូច្នេះ សំណើរបស់ កសព ត្រូវតែបដិសេធចោល ។

## ខ. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្ម ទាក់ទងនឹងអនីត្យានុកូលភាពនៃវិធានផ្ទៃក្នុង គឺមិនសមហេតុផល

១៨. សេចក្តីសម្រេចថ្មីៗនេះដោយអង្គជំនុំជម្រះសាលាដំបូងលើអញ្ញត្រកម្មរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អវតក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ("សេចក្តីសម្រេចអំពីអញ្ញត្រកម្ម") បានលើកមកពិភាក្សានូវបញ្ហាជាច្រើនដែលលើកឡើងនៅក្នុងសំណើរបស់ កសព ប៉ុន្តែវាជារឿងមិនហេតុផល ។ នៅក្នុងសេចក្តីសម្រេចអំពីអញ្ញត្រកម្ម អង្គជំនុំជម្រះសម្រេចថាគ្មានអ្វីមកហាមឃាត់មិនឲ្យអនុម័តវិធានផ្ទៃក្នុងដោយកិច្ចប្រជុំពេញអង្គមួយឡើយ ដែលត្រូវបានកោះប្រជុំសម្រាប់គោលបំណងនោះ[19] ហើយហេតុដូច្នេះ សំណើសុំមោឃភាពវិធានផ្ទៃក្នុង ត្រូវបដិសេធចោល ។ សំណើសុំមោឃភាពដីកាបង្គាប់ត្រៀមរៀបចំសវនាការ ក៏ត្រូវបដិសេធចោលផងដែរ ដោយសារផ្នែកតែមួយគត់នៃដីកាបង្គាប់ត្រៀមរៀបចំសវនាការដែលត្រូវបានលើកឡើងដោយជនជាប់ចោទ គឺជាប់ពាក់ព័ន្ធទៅនឹងផ្នែកដែលតម្រូវឲ្យភាគីដាក់បញ្ជីមួយនៃអង្គហេតុហេតុដែលមិនជំទាស់ ដោយអនុលោមតាមវិធាន ៨០(៣)(ង) ហើយវិធាននេះដែលគ្រាន់តែតម្រូវឲ្យភាគីដាក់បញ្ជីមួយនៃអង្គហេតុដែលមិនមានការជំទាស់ គឺស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តនៅតុលាការផ្សេងៗ និងសិទ្ធិជាសារវត្តរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌"[20] ។

---

[19] សេចក្តីសម្រេចអំពីអញ្ញត្រកម្ម នៅកថាខណ្ឌទី ៥ ។

[20] សេចក្តីសម្រេចអំពីអញ្ញត្រកម្ម នៅកថាខណ្ឌទី ៩ ។

១៩. ជាបឋម គេគួរតែកត់សម្គាល់ថាដំណោះស្រាយដែល កសព កំពុងតែស្នើសុំនេះ គឺជាប្រភេទមួយនៃការដាក់ទណ្ឌកម្ម (ជាពិសេស ការច្រានចោលជាមុននូវភស្តុតាង) ចំពោះការមិនគោរពតាមដីកាបង្គាប់ត្រៀមរៀបចំសវនាការ ។ ទណ្ឌកម្មបែបនេះមិនមានចែងនៅក្នុងវិធាន ៨០ ក៏ដូចជាដីកាបង្គាប់ត្រៀមរៀបចំសវនាការដែរ ហើយនៅពេលជាមួយគ្នានេះ ទណ្ឌកម្មនេះផ្ទុយទៅនឹងបទប្បញ្ញត្តិច្បាប់កម្ពុជាដែលនៅជាធរមាន (មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ ម្យ៉ាងវិញទៀត ដោយមិនគិតពីឋានៈ ឬនីត្យានុកូលភាពនៃវិធាន ៨០ ឬដីកាបង្គាប់ត្រៀមរៀបចំសវនាការ ដំណោះស្រាយដែលស្នើឡើងដោយ កសព មិនត្រូវបានគាំទ្រដោយប្រភពច្បាប់ទាំងនេះឡើយ ហើយមួយវិញទៀត វាផ្ទុយទៅនឹងច្បាប់កម្ពុជាទៀតផង ។ ការកត់សម្គាល់នេះ កំណត់លទ្ធផលរបស់នីតិវិធី ហើយដូច្នេះ សំណើរបស់ កសព ត្រូវតែបដិសេធចោល ។

២០. សម្រាប់គោលបំណងនៃសារណាចម្លើយតបនេះ មេធាវីការពារក្តីមិនបានអះអាងថាកិច្ចប្រជុំពេញអង្គគ្មានអំណាចដើម្បីអនុម័តប្រព័ន្ធមួយរបស់វិធានផ្ទៃក្នុង(ទាំងស្រុង)បែបនេះទេ[21] ។ ផ្ទុយមកវិញមេធាវីការពារក្តីស្នើសូមឲ្យពិចារណាថា *បទប្បញ្ញត្តិជាក់លាក់មួយ*[22] នៃវិធានផ្ទៃក្នុង ផ្ទុយទៅនឹងច្បាប់នៅពេលពិចារណាវិធាននេះព្រមគ្នានឹងសំណើសុំដំណោះស្រាយ ដោយសារវារំលោភទៅលើការការពារដែលផ្តល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា រំលោភសិទ្ធិជាមូលដ្ឋានរបស់កូនក្តីយើងខ្ញុំក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងរំលោភរដ្ឋធម្មនុញ្ញកម្ពុជា[23]។ អាស្រ័យហេតុនេះ បញ្ហានេះគឺជាបញ្ហាមួយដែលខុសគ្នាទៅនឹងបញ្ហាដែលត្រូវបានសម្រេចរួចមកហើយនៅក្នុងដីកាបង្គាប់ត្រៀមរៀបចំសវនាការ[24] ។

---

[21] សម្រាប់គោលបំណងនៃសារណាឆ្លើយតបនេះ មេធាវីការពារមិនអះអាងថាវិធាន ៨០(៣)(ង) (បទបញ្ញត្តិទាក់ទងនឹងអង្គហេតុដែលមិនមានការជំទាស់) រំលោភសិទ្ធិរបស់ នួន ជា ដែលជាការអះអាងមួយត្រូវបានពិចារណារួចមកហើយ (និងត្រូវបានបដិសេធចោលផងដែរ) នៅក្នុងសេចក្តីសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ។ អង្គជំនុំជម្រះមិនទាន់បដិសេធនៅឡើយលើភាពស្របច្បាប់របស់វិធាន ៨០(៣)(ខ) និង(ឃ) ហើយនៅផ្នែកនៃដីកាបង្គាប់ត្រៀមរៀបចំសវនាការដែលផ្អែកលើបទបញ្ញត្តិទាំងនេះ ។

[22] វិធានជាក់លាក់ចំនួនពីរ គឺវិធាន ៨០(៣)(ខ) និងវិធាន ៨០(៣)(ឃ) ។

[23] សូមមើលកថាខណ្ឌទី២១-២៦ នៃចម្លើយតបនេះ ។ និយាយឲ្យត្រឹមត្រូវទៅគេអាចទាញទឡ្ហីករណ៍ថាការអនុម័តវិធាន ៨០(៣)(ខ) និង(ឃ) បែបនេះ មិនរំលោភមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ប៉ុន្តែការអនុញ្ញាតដំណោះស្រាយ

### គ. ដំណោះស្រាយដែលស្នើសុំដោយសហព្រះរាជអាជ្ញា រំលោភរដ្ឋធម្មនុញ្ញកម្ពុជា

២១. ការអនុញ្ញាតឲ្យមានដំណោះស្រាយដែលស្នើសុំដោយ កសព (ការច្រានចោលភស្តុតាងដោយផ្អែកលើវិធាន ៨០ (៣)(ខ) និង(ឃ) នៃវិធានផ្ទៃក្នុង និងដីកាបង្គាប់ត្រៀមរៀបចំសវនាការ នឹងនាំឲ្យមានការរំលោភបំពានដល់រដ្ឋធម្មនុញ្ញកម្ពុជា[25]។ ក្នុងសេណារីយ៉ូនោះ (ការអនុញ្ញាតឲ្យមានដំណោះស្រាយតាមការស្នើសុំរបស់ កសព) ការបញ្ចូលគ្នានៃការអនុម័តវិធាន ៨០ (៣)(ខ) និង(ឃ) ដីកាបង្គាប់ត្រៀមរៀបចំសវនាការ និងការអនុញ្ញាតឲ្យមានដំណោះស្រាយជាបន្តបន្ទាប់តាមសំណើរបស់ កសព នឹងមិនត្រឹមតែរំលោភមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរំលោភដល់បញ្ញត្តិជាច្រើនដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាទៀតផង ។

២២. ជាបឋម ការអនុម័តវិធាន៨០(៣)(ខ) និង(ឃ) នៃវិធានផ្ទៃក្នុង (ក្នុងសេណារីយ៉ូនេះ) ត្រូវតែបានយល់ថារំលោភមាត្រា ៥១ និង ៩០ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលបានចែងថា “អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ [...][26]”

---

ដែលស្នើសុំដោយសហព្រះរាជអាជ្ញា នឹងមានន័យថាវិធាន ៨០(៣)(ខ) និង(ឃ) នឹងត្រូវបានអនុវត្ត(ឬបកស្រាយ) ក្នុងន័យមួយដែលនឹងឈានទៅរក (សម្របសម្រួល) ការរំលោភមាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌជាមិនខានឡើយ ។

[24] ការដែលថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានរំលោភបំពាននៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ននេះ បានធ្វើឲ្យករណីនេះខុសគ្នាពីបញ្ហានេះនៅក្នុងដំណើរការនីតិវិធីទាក់ទងនឹងអញ្ញត្រកម្ម ដោយសារតែនៅក្នុងករណីនោះអង្គជំនុំជម្រះបានពិចារណាតែវិធាន ៨០(៣)(ង) ដែលអង្គជំនុំជម្រះយល់ឃើញថា វាស៊ីសង្វាក់គ្នាជាមួយការអនុវត្តនៅតុលាការផ្សេងៗទៀត និងសិទ្ធិជាសារវត្តរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ ដោយមិនគិតថាគេយល់ស្របជាមួយការវាយតម្លៃនេះដោយអង្គជំនុំជម្រះ វាមានន័យយ៉ាងច្បាស់លាស់ថាសិទ្ធិដែលផ្តល់ឲ្យជនជាប់ចោទនៅចំពោះតុលាការកម្ពុជាដើម្បីដាក់វត្ថុតាងរហូតទល់នឹងការបិទការពិភាក្សាដេញដោល ត្រូវបានរំលោភបំពានដោយអភិក្រមដែលឃោសនាដោយសហព្រះរាជអាជ្ញា ។

[25] ភាពស្មុគស្មាញមួយក្នុងការរៀបចំចម្លើយតបនេះ គឺថាអនុភាពផ្នែកច្បាប់/ផលវិបាកផ្នែកច្បាប់នៃវិធាន៨០(ខ) និង (ឃ) និងដីកាជាបន្តបន្ទាប់បង្គាប់ឲ្យរៀបចំសវនាការគឺនៅតែមិនច្បាស់ *ដរាបណា* អង្គជំនុំជម្រះសាលាដំបូងមិនទាន់សម្រេចលើសំណើរបស់ កសព ។ ដូច្នេះដើម្បីលើកអំណះអំណាងរបស់ខ្លួន មេធាវីការពារក្តីត្រូវបានគេបង្ខំឲ្យចាត់ទុក *arguendo* ជាវចនាសម្ព័ន្ធច្បាប់ដែលនឹងយកមកអនុវត្តប្រសិនបើដំណោះស្រាយដែល កសព បានស្នើសុំ ត្រូវបានអនុញ្ញាត។

[26] មាត្រា៥១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ហើយថា "រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិ ។ អំណាចនេះរដ្ឋសភាមិនអាចប្រគល់ឲ្យអង្គការ ឬបុគ្គលណាមួយបានឡើយ [...]"[27]។

២៣. ការអនុម័តវិធាន ៨០(៣)(ខ) និង(ឃ) ត្រូវតែចាត់ទុកថាជាសកម្មភាពនៃការតាក់តែងច្បាប់ដោយកិច្ចប្រជុំពេញអង្គ ។ នេះជាការពិតព្រោះអនុភាពសំខាន់បំផុត (តាមការសន្មត) របស់វិធាននេះ គឺមានប្រៀបជាវៀងរហូត (ហើយដែលសំខាន់គឺលុបបំបាត់) លើបទប្បញ្ញត្តិយ៉ាងច្បាស់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[28] ប្រសិនបើដំណោះស្រាយដែលបានស្នើសុំត្រូវបានអនុញ្ញាតនោះ ។ បទប្បញ្ញត្តិដែលមានប្រៀបជាវៀងរហូតនេះដែលធ្វើក្នុងនាមរដ្ឋសភា គឺជាការបង្កើតច្បាប់ ។

២៤. ការអនុញ្ញាតឲ្យមានដំណោះស្រាយដែលបានស្នើសុំ[29] នឹងរំលោភមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាផងដែរ ដែលចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់"។ ពាក្យថា "ត្រឹមត្រូវតាមបញ្ញត្តិច្បាប់" ត្រូវតែយល់ឃើញថាស្រប*តាមច្បាប់កម្ពុជា* ។ មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺជាច្បាប់កម្ពុជា ហើយកំពុងដំណើរការប្រកបដោយប្រសិទ្ធិភាពនៅពេលបច្ចុប្បន្ននេះ ។ ដូច្នេះមាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវតែបានគេចាត់ទុកថាជាច្បាប់ដែលនៅជាធរមាន ហើយការចោទប្រកាន់ត្រូវតែធ្វើឡើងឲ្យស្របតាមមាត្រានេះ ។ ការចោទប្រកាន់មិនគួរធ្វើឡើងតាមប្បញ្ញត្តិនៃវិធានផ្ទៃក្នុងរបស់តុលាការដែលត្រូវបានធ្វើអន្តរជាតូបនីយកម្មឡើយ ព្រោះថាយ៉ាងហោចណាស់នៅតុលាការបែបនេះប្បញ្ញត្តិ (ឬអនុភាពរបស់វា) គឺផ្ទុយគ្នាទៅនឹងការការពារដែលផ្តល់ឲ្យដោយច្បាប់កម្ពុជាដែលនៅជាធរមាន ។ ដូចគ្នានេះដែរ ការអនុញ្ញាតឲ្យមានដំណោះស្រាយដែលបានស្នើសុំដោយ កសព នឹងរំលោភមាត្រា

---

[27] មាត្រា៩០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (គូសបញ្ជាក់បន្ថែម)។

[28] អនុភាពអវិជ្ជមានជាអចិន្ត្រៃយ៍ដោយចេតនាអាចកើតឡើងតែតាមរយៈវិធាន៨០(៣)(ខ)និង(ឃ) (និងដីកាជាបន្តបន្ទាប់បង្គាប់ឲ្យត្រៀមរៀបចំសវនាការ) ប្រសិនបើបញ្ញត្តិដាក់លាក់ក្នុងវិធានផ្ទៃក្នុងទាំងនេះត្រូវបានគេចាត់ទុកថាមានឋានៈស្មើនឹង ឬមានឋានៈខ្ពស់ជាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលជាច្បាប់កម្ពុជាដាក់ឲ្យប្រើប្រាស់យ៉ាងត្រឹមត្រូវដោយសភាជាតិកម្ពុជាទៀតនោះ។ ដូច្នេះ ក្នុងសេណារីយ៉ូនេះ សេចក្តីសន្និដ្ឋានគឺថាកិច្ចប្រជុំពេញអង្គបានតាក់តែងច្បាប់ដោយខ្លួនឯងដោយអនុម័តវិធាន៨០(៣)(ខ) និង (ឃ) ដោយរំលោភការហាមឃាត់ដែលមានចែងក្នុងមាត្រា៥១ និង៩០ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

[29] ផ្អែកតាមមាត្រា វិធាន៨០(៣) (ខ) និង (ឃ) និងដីកាបន្តបន្ទាប់បង្គាប់ឲ្យត្រៀមរៀបចំសវនាការ។

១១០ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងថា "ការជំរះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្រ្តខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន" ។ ជាថ្មីម្តងទៀត "នីតិវិធីនិងច្បាប់ដែលនៅជាធរមាន" ត្រូវតែយល់ឃើញថាជានីតិវិធី និងច្បាប់*កម្ពុជា*។

២៥. និយាយជាទូទៅជាងនេះទៀត មាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជាធានាសិទ្ធិរបស់ នួន ជា ដូចដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិជាច្រើនស្តីពីសិទ្ធិមនុស្ស ។ ការចោទប្រកាន់ស្របតាមច្បាប់ដែលនៅជាធរមាន ត្រូវតែបានចាត់ទុកថាជាការស្របតាមសិទ្ធិមនុស្ស[30]។ ចំណុចនេះក៏មានន័យផងដែរថា ជនសង្ស័យត្រូវតែអាចលើកមកសំអាងបទប្បញ្ញត្តិផ្លូវការក្នុងច្បាប់ជាតិដែលផ្តល់ឱ្យគាត់នូវសិទ្ធិការពារដ៏រឹងមាំទាក់ទងនឹងការដាក់ភស្តុតាង ។ ម្យ៉ាងវិញទៀត វាជាសិទ្ធិសារវន្តរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងការទទួលបានការការពារជាផ្លូវការ ដែលឱ្យផ្តល់ពួកគេដោយច្បាប់ជាតិ ។ ការអនុញ្ញាតឱ្យមានដំណោះស្រាយដែលបានស្នើសុំដោយ កសព គួបផ្សំនឹងវិធាន ៨០(៣)(ខ) និង(ឃ) និងដីកាបង្គាប់ត្រៀមរៀបចំសវនាការបានរារាំង នួន ជា មិនឱ្យធ្វើដូច្នេះបានឡើយ ។ ដូច្នេះបញ្ញត្តិទាំងនេះបានរំលោភសិទ្ធិជាមូលដ្ឋានរបស់គាត់ និងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។

២៦. និយាយឱ្យខ្លី តាមទស្សវិស័យរដ្ឋធម្មនុញ្ញ ការអនុញ្ញាតឱ្យមានដំណោះស្រាយដែលបានស្នើសុំដោយ កសព ដោយផ្អែកលើបញ្ញត្តិច្បាប់ដែលមានចែងក្នុងវិធាន៨០(៣)(ខ) និង(ឃ) និងដីកាបង្គាប់ឱ្យត្រៀមរៀបចំសវនាការ នឹងនាំឱ្យមានលទ្ធផលមួយដែលការការពារក្តីមិនអាចធ្វើទៅរួចឡើយ ។ អាស្រ័យដោយមូលហេតុនេះ សំណើរបស់ កសព ត្រូវតែបដិសេធចោល ។

## ឃ.គួរតែធ្វើការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ

២៧. ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងមិនមានចេតនាបដិសេធចោលសំណើរបស់ កសព តែមេធាវីការពារក្តីស្នើថា អង្គជំនុំជម្រះសាលាដំបូងគួរតែពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ[31]អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

---

[30] សូមមើល ឧទាហរណ៍ មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋដែលតម្រូវឱ្យមានការចោទប្រកាន់ស្របតាមច្បាប់។

[31] តាមរយៈការដាក់ករណីនេះទៅកាន់អង្គជំនុំជម្រះតុលាការកំពូល។

មាត្រា១៩ នៃច្បាប់នេះចែងថា "បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្ដីណាមួយហើយរឿងក្ដីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកពីធម្មនុញ្ញភាពនូវបទបញ្ញត្តិណាមួយនៃច្បាប់ឬសេចក្ដីសម្រេច របស់ស្ថាប័ននានាដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវ័ន្តណាមួយរបស់គេជូនតុលាការបាន"។

២៨. ក្នុងដំណើរការនីតិវិធីទាំងនេះ សំណួរសំខាន់ៗជាច្រើនទាក់ទងនឹងធម្មនុញ្ញភាព និងសិទ្ធិសារវ័ន្តរបស់ នួន ជា គឺមានទំនាក់ទំនងនឹងគ្នា ។ គេមិនអាចបដិសេធបានទេថាដំណោះស្រាយដែលស្នើសុំដោយ កសព នឹងប៉ះពាល់ដល់សិទ្ធិទទួលបានមេធាវីការពារក្ដីដោយគ្មានលក្ខខណ្ឌដែលផ្ដល់ឲ្យប្រជាជនកម្ពុជាគ្រប់រូបដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។ ម្យ៉ាងទៀត យ៉ាងហោចណាស់គេអាចលើកអំណះអំណាងថា ដំណោះស្រាយដែលស្នើសុំនេះ គឺជាការរំលោភដល់រដ្ឋធម្មនុញ្ញ[32]។ លើសពីនេះទៀត យ៉ាងហោចណាស់គេគួរតែទទួលស្គាល់ថាវាមានលេចឡើងនូវការខ្វែងគំនិតគ្នាដោយសុចរិតរវាងភាគីទាក់ទងនឹងស្ថានភាព(នៃបទបញ្ញត្តិមួយចំនួន)ក្នុងវិធានផ្ទៃក្នុង ដែលឥឡូវនេះបានក្លាយជាចំណុចកំពូលនៃជម្លោះនៅពេលនេះទាក់ទងនឹងធម្មនុញ្ញភាពនៃវិធាន ៨០(៣)(ខ) និង (ឃ) និងដីកាបង្គាប់ជាបន្តបន្ទាប់ឲ្យត្រៀមរៀបចំសវនាការ ។

២៩. អនុលោមតាមមាត្រា១៩ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ នួន ជា ស្នើឲ្យពិចារណាថាការអនុញ្ញាតដំណោះស្រាយដែលស្នើសុំដោយ កសព នឹងប៉ះពាល់ដល់សិទ្ធិជាសារវន្ត និងសេរីភាពរបស់គាត់ដូចដែលបានការពារដោយមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយអាស្រ័យដោយមូលហេតុទាំងអស់ដែលបានលើកឡើងក្នុងខណ្ឌទី២២-២៦ ដំណោះស្រាយនេះនឹងនាំឲ្យប៉ះពាល់យ៉ាងច្រើនដល់រដ្ឋធម្មនុញ្ញកម្ពុជា ។ អាស្រ័យហេតុនេះ គាត់សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីវាយតម្លៃពីធម្មនុញ្ញភាពនៃដំណោះស្រាយដែលបានស្នើសុំដោយ កសព[33] ។

---

[32] *សូមមើល* កថាខណ្ឌ ២១ ដល់២៦ នៃចម្លើយតបនេះ។

[33] ពិតណាស់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ No.040/002/2001 ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានសម្រេចរួចហើយថាច្បាប់ស្ដីពីការបង្កើត អវតក គឺស្របតមធម្មនុញ្ញកម្ពុជា។ មេធាវីការពារក្ដីមិនមានបំណងលើរើបញ្ហានេះម្ដងទៀតឡើយ។ ផ្ទុយទៅវិញ មេធាវីការពារក្ដីមានបំណងបង្កើតឲ្យមានធម្មនុញ្ញភាពនៃដំណោះស្រាយដែលបានស្នើសុំដោយ កសព វិធាន៨០(៣)(ខ) និង (ឃ) នៃវិធានផ្ទៃក្នុង និងការពឹងផ្អែកជាបន្តបន្ទាប់លើបទបញ្ញត្តិទាំងនេះក្នុងការអនុម័តដីកាបង្គាប់ឲ្យត្រៀមរៀបចំសវនាការ។

៣០. ជាងនេះទៅទៀត នួន ជា ស្នើឱ្យពិចារណាថាការអនុម័តវិធាន៨០(៣)(ខ) និង(ឃ) ដោយកិច្ចប្រជុំពេញអង្គ និងការចេញដីកាបង្គាប់ត្រៀមរៀបចំសវនាការដោយអង្គជំនុំជម្រះបានប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់គាត់[34]។ បន្ថែមពីលើនេះ ការអនុម័តវិធាន៨០(៣)(ខ) និង(ឃ) បានរំលោភរដ្ឋធម្មនុញ្ញកម្ពុជា ព្រោះវិធាននេះត្រូវបានអនុម័តដោយរំលោភទៅនឹងការហាមឃាត់ការបង្កើតច្បាប់ដោយប្រព័ន្ធតុលាការ[35] ។ ដូច្នេះ នួន ជា សូមស្នើឱ្យអង្គជំនុំជម្រះពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីវាយតម្លៃពីធម្មនុញ្ញភាពនៃការអនុម័តវិធាន ៨០(៣)(ខ) និង(ឃ) និងការចេញដីកាបង្គាប់ជាបន្តបន្ទាប់ត្រៀមរៀបចំសវនាការ ។

៣១. មេធាវីការពារក្តីសូមជម្រុញឱ្យអង្គជំនុំជម្រះសាលាដំបូង ដាក់បញ្ហាទាំងនេះទៅអង្គជំនុំជម្រះតុលាការកំពូល[36] ដើម្បីពិភាក្សា ហើយបន្ទាប់មកដាក់ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយអនុលោមតាមមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

៣២. យ៉ាងហោចណាស់មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងចោទសួរសំណួរខាងក្រោមនេះទៅក្រុមប្រឹក្សាធម្មនុញ្ញ៖

- តើដំណោះស្រាយដែលស្នើសុំដោយ កសព ប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន និងសេរី

---

[34] វិធាន៨០(៣) (ខ) និង (ឃ) ចែងពីមូលដ្ឋានច្បាប់ដែលនឹងត្រូវគេប្រើដើម្បីដកភស្តុតាងដែលបានដាក់បន្ទាប់ពីការចាប់ផ្តើមសវនាការ។ ដូច្នេះ បញ្ញត្តិទាំងនេះ នឹងក្លាយជាមធ្យោបាយដើម្បីរំលោភការការពារដែលបានផ្តល់ឱ្យដោយមាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដោយនាំឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់លោក នួន ជា (ចំណុចសំខាន់ពាក់ព័ន្ធក្នុងមាត្រា១៩)។ ការអនុម័តលើវិធាន ៨០(៣)(ខ) និង (ឃ) និងដីកាបង្គាប់ឱ្យត្រៀមរៀបចំសវនាការក៏បានរំលោភដល់សិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់លោក នួន ជា ផងែរព្រោះវាបណ្តាលឱ្យមានកាតព្វកិច្ច (ដោយចេតនា)មួយចំនួនដែលមិនមានក្នុងច្បាប់កម្ពុជា ហើយដែលធ្វើឱ្យមេធាវីការពារក្តីរបស់គាត់ជួបភាពស្មុគស្មាញ។ ការដាក់បញ្ជីឯកសារនឹងក្លាយជាការបង្ខំឱ្យមេធាវីក្តី ប្រាប់ កសព ពីយុទ្ធសាស្ត្រការពារក្តីរបស់ខ្លួន សូម្បីតែនៅមុនពេលដែល កសព បង្ហាញ ឯកសាររបស់ខ្លួន ។ដូចដែលបានលើកឡើងយ៉ាងច្បាស់ក្នុងវិធាន ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា “ការលាតត្រដាង” បែបនេះ អាចជាដំណោះស្រាយដែលមានការទទួលយកច្រើនជាងក្នុងប្រព័ន្ធច្បាប់កុម៉ុងឡ (common law) ប៉ុន្តែមិនមែនក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law)ឡើយ ។

[35] *សូមមើល*កថាខណ្ឌទី២២ ដល់២៣ នៃចម្លើយតបនេះ។

[36] នេះគួរតែជាតុលាការកំពូលរបស់កម្ពុជា “ទៀងទាត់” មិនមែនជាអង្គជំនុំជម្រះតុលាការកំពូលនៅ អវតក ឡើយ។

ភាព[37]របស់ នួន ជា ដែរ ឬអត់ ដោយសារដំណោះស្រាយនេះនឹងរំលោភបំពានដោយផ្ទាល់ទៅលើមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះ? តើដំណោះស្រាយដែលបានស្នើសុំដោយ កសព ជាការផ្ទុយនឹងរដ្ឋធម្មនុញ្ញដែរឬទេ ក្នុងន័យផ្សេងទៀតនោះ?។

- តើការអនុម័តវិធាន៨០(៣)(ខ) និង(ឃ) បង្កើតបានជាការរំលោភដោយកិច្ចប្រជុំពេញអង្គទៅលើអំណាចផ្តាច់មុខរបស់រដ្ឋសភាក្នុងការតាក់តែង/អនុម័តច្បាប់ (រដ្ឋធម្មនុញ្ញមាត្រា៩០) ដែរ ឬទេ?
- តើការអនុម័តមាត្រា៨០ (៣)(ខ) និង(ឃ) និងដីកាជាបន្តបន្ទាប់បង្គាប់ត្រៀមរៀបចំសវនាការបានប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់ នួន ជា ដូចដែលបានការពារដោយច្បាប់កម្ពុជាដែរ ឬទេ? តើបញ្ញត្តិទាំងនេះផ្ទុយនឹងធម្មនុញ្ញ ដែរឬទេ ក្នុងន័យផ្សេងទៀតនោះ?

៣៣. ដោយពិចារណាឃើញថាសំណួរសំខាន់ៗអំពីច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ស្ថិតនៅភាពគ្រោះថ្នាក់ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាច្បាស់ជាត្រូវវាយតម្លៃសំណួរទាំងនេះឲ្យបានល្អបំផុត ។ ដូច្នេះ មេធាវីការពារក្តីសូមជម្រុញឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តបទដ្ឋានពិនិត្យដែលមានលក្ខណៈទូលំទូលាយនៅពេលវាយតម្លៃពីសំណើរបស់មេធាវីការពារក្តីសុំបញ្ជូន បញ្ហាទាំងនេះទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

## VI. សេចក្តីសន្និដ្ឋាន និងសំណើ

៣៤. អាស្រ័យលើមូលហេតុខាងលើ មេធាវីការពារក្តីតទៅនេះសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោទសំណើរបស់ កសព ព្រោះដំណោះស្រាយដែលបានស្នើសុំនេះ រំលោភដោយផ្ទាល់ទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

៣៥. ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងមិនមានចេតនាបដិសេធចោលសំណើរបស់ កសព ទាំងស្រុង ឬមួយផ្នែកទេ នោះមេធាវីការពារក្តីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីវាយតម្លៃពីធម្មនុញ្ញភាពនៃ (ក)ដំណោះស្រាយដែល

[37] សូមមើលមាត្រា១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

បានស្នើសុំដោយ កសព និង(ខ)ការអនុម័តលើវិធាន៨០ (៣)(ខ) និង (ឃ) និងដីកាបង្គាប់រៀបចំសវនាការ និង(គ)វាយតម្លៃឱ្យបានទូលំទូលាយជាងនេះអំពីភាពស៊ីសង្វាក់គ្នានៃដំណោះស្រាយដែលបានស្នើសុំដោយ កសព និងបញ្ញត្តិច្បាប់ពាក់ព័ន្ធជាមួយនឹងសិទ្ធិជាមូលដ្ឋាន និងសេរីភាពរបស់ នួន ជា។

៣៦. សម្រាប់គោលបំណងនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែដាក់សំណួរដែលបានលើកឡើងក្នុងកថាខណ្ឌទី៣២ និងសំណួរដទៃទៀត ឬការអត្ថាធិប្បាយផ្សេងដែលអង្គជំនុំជម្រះចាត់ទុកថាមានការពាក់ព័ន្ធ ទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ហើយបន្ទាប់មកបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ជាងនេះទៅទៀតមេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងរង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះតុលាការកំពូល និង/ឬពីក្រុមប្រឹក្សាធម្មនុញ្ញលើបញ្ហានេះជាមុនសិនមុននឹងពេលសម្រេចលើសំណើរបស់ កសព។

៣៧. មេធាវីការពារក្តីសូមស្នើសុំឱ្យមានសវនាការជាសាធារណៈលើសំណើរបស់ កសព ។ ដំណើរការនីតិវិធីទាំងនេះពាក់ព័ន្ធនឹងសំណួរសំខាន់ៗអំពីច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា និងសិទ្ធិជាមូលដ្ឋានក្នុងការទទួលក្នុងការការពារក្តី ។ បញ្ហាដែលមានសារសំខាន់បែបនេះត្រូវតែលើកយកមកពិភាក្សាក្នុងសវនាការជាសាធារណៈ ។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE